ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

**ធនាគារជាតិ នៃ កម្ពុជា**

លេខ........................................................

## សុន្ទរកថាបើក
## ឯកឧត្តម ជា ចាន់តូ ទេសាភិបាលធនាគារជាតិនៃកម្ពុជា
## ពិធីអបអរសាទរខួបអនុស្សាវរីយ៍លើកទី៣៨ នៃប្រតិបត្តិការធនាគារកណ្តាល
## រាជធានីភ្នំពេញ ថ្ងៃទី៨ ខែតុលា ឆ្នាំ២០១៧

**សូមគោរព៖**

**ឯកឧត្តម លោកជំទាវ លោក លោកស្រី នាងកញ្ញាទាំងអស់ ជាទីមេត្រី!**

ថ្ងៃនេះ ខ្ញុំមានសេចក្តីសោមនស្សរីករាយជាអនេក ដែលបានចូលរួមក្នុងពិធីរំឭកខួបអនុស្សាវរីយ៍លើកទី៣៨ នៃការបង្កើតធនាគារជាតិនៃកម្ពុជាឡើងវិញថ្ងៃ១០ តុលា ១៩៧៩ - ១០ តុលា ២០១៧។ ការប្រារព្ធពិធីអបអរសាទរនៅថ្ងៃអាទិត្យនេះ មុនពីរថ្ងៃនៃខួបបង្កើតធនាគារជាតិនៃកម្ពុជាឡើងវិញ គឺដើម្បីបង្កលក្ខណៈឱ្យមន្ត្រី-បុគ្គលិកយើងទាំងនៅស្នាក់ការកណ្តាលនិងសាខារាជធានី-ខេត្ត និងនិស្សិត សរុបប្រមាណ ៩០០នាក់ បានចូលរួមឱ្យច្រើនកុះករ ដើម្បីញ៉ាំងឱ្យពិធីនេះប្រព្រឹត្តទៅដោយភាពអធិកអធមនិងចងចាំថែមទៀត ជាពិសេសផ្តល់ឱកាសឱ្យយុវជនយើង បានស្វែងយល់ពីប្រវត្តិនៃការកកើតនិងការវិវត្តនៃប្រព័ន្ធធនាគារតាំងពីអតីតកាលរហូតដល់បច្ចុប្បន្ន។ ក្រោយថ្ងៃមហាជ័យជម្នះ ៧ មករា ដែលបានរំដោះប្រជាជនកម្ពុជាចេញពីរបបប្រល័យពូជសាសន៍ ប៉ុល ពត ការងារចម្បងមួយក្នុងចំណោមការងារអាទិភាពនានា គឺការបង្កើតធនាគារកណ្តាល ដែលនៅពេលនោះផ្តើមចេញពីបាតដៃទទេ គ្មានធនធានមនុស្សគ្រប់គ្រាន់ ខ្វះជំនាញ បច្ចេកវិទ្យា និងហិរញ្ញវត្ថុ។ ការបង្កើតធនាគារកណ្តាលយ៉ាងឆាប់រហ័សនេះ មានគោលបំណងដាក់ឱ្យចរាចរឡើងវិញនូវប្រាក់រៀលដែលតំណាងឱ្យ



ប្រអប់សំបុត្រលេខ ២៥, ផ្លូវលេខ ២២-២៤ មហាវិថី ព្រះនរោត្តម រាជធានីភ្នំពេញ, ទូរស័ព្ទ : (៨៥៥-២៣) ៧២២ ៥៦៣, ទូរស័ព្ទ . ទូរសារ : (៨៥៥-២៣) ៤២៦ ១១៧

អធិបតេយ្យជាតិ និងការរស់រានឡើងវិញនៃប្រជាជន។ ការបង្កើតធនាគារកណ្តាលឡើងវិញនេះក៏ជាព្រឹត្តិការណ៍ប្រវត្តិសាស្ត្រដ៏សំខាន់ និងបានរួមចំណែកក្នុងការកសាងមូលដ្ឋានគ្រឹះនៃការអភិវឌ្ឍសេដ្ឋកិច្ចជាតិ ជាបន្តបន្ទាប់រហូតមកដល់សព្វថ្ងៃ។ ដូច្នេះ ថ្ងៃនេះ យើងជួបជុំគ្នាដើម្បីអបអរសាទរចំពោះសមិទ្ធផលដែលប្រព័ន្ធធនាគារយើងសម្រេចបាន ក្នុងរយៈពេល ៣៨ឆ្នាំកន្លងមក។ ខ្ញុំសូមយកឱកាសនេះ ដើម្បីសម្តែងនូវការដឹងគុណដ៏ជ្រាលជ្រៅបំផុតចំពោះ សម្តេចអគ្គមហាធម្មពោធិសាល ជា ស៊ីម, សម្តេចអគ្គមហាពញាចក្រី ហេង សំរិន, និងសម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន ព្រមទាំងឥស្សរជនខ្មែរយើងទាំងអស់ដែលបានបូជាអាយុ ជីវិត និងកម្លាំងកាយចិត្ត ដើម្បីរំដោះប្រជាជននិងសង្គ្រោះប្រទេសជាតិចេញពីរបបប្រល័យពូជសាសន៍ ប៉ុល ពត ហើយបានស្តារ កសាង និងអភិវឌ្ឍសេដ្ឋកិច្ចនិងសង្គមជាតិឱ្យមានការរីកចម្រើនរហូតក្លាយជាប្រទេសមានចំណូលមធ្យម និងការរក្សាបានដ៏រឹងមាំនូវសុខសន្តិភាព ស្ថិរភាពនយោបាយ និងសណ្តាប់ធ្នាប់សាធារណៈ។ ខ្ញុំក៏សូមសម្តែងការកោតសរសើរនិងអំណរគុណយ៉ាងខ្លាំងចំពោះ អតីតទេសាភិបាល ក្រុមប្រឹក្សាភិបាលថ្នាក់ដឹកនាំ និងមន្ត្រីបុគ្គលិកទាំងអស់ ដែលបានរួមចំណែកក្នុងកិច្ចកសាងប្រព័ន្ធធនាគារកម្ពុជាឱ្យមានការអភិវឌ្ឍដូចបច្ចុប្បន្ន។

ក្នុងរយៈពេល៣៨ឆ្នាំចុងក្រោយនេះ ជាពិសេសបន្ទាប់ពីកម្ពុជាទទួលបានសន្តិភាពពេញលេញ ចាប់ពីឆ្នាំ១៩៩៨មក ប្រព័ន្ធធនាគារបានបោះជំហានទៅមុខយ៉ាងរឹងមាំទាំងផ្នែករូបវន្តនិងគុណភាព ហើយបានដើរតួនាទីយ៉ាងសំខាន់ក្នុងការរួមចំណែកអភិវឌ្ឍសេដ្ឋកិច្ចនិងសង្គម តាមរយៈការគាំទ្រនិងជំរុញកំណើនសេដ្ឋកិច្ច ការលើកកម្ពស់បរិយាប័ន្នហិរញ្ញវត្ថុ និងការកាត់បន្ថយភាពក្រីក្រ ហើយសមិទ្ធផលទាំងនេះត្រូវបានទទួលស្គាល់ដោយមជ្ឈដ្ឋាន

ជាតិនិងអន្តរជាតិ។ ជាក់ស្តែង រាជរដ្ឋាភិបាលបានចាត់ទុកប្រព័ន្ធធនាគារថាបានដើរតួនាទីស្នូលក្នុងការគាំទ្រកំណើនសេដ្ឋកិច្ច ស្ថិរភាពម៉ាក្រូសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ កាត់បន្ថយភាពក្រីក្រនិងជំរុញសមាហរណកម្មសេដ្ឋកិច្ចកម្ពុជាទៅក្នុងតំបន់និងពិភពលោក។ ក្នុងរយៈពេល១៦ឆ្នាំចុងក្រោយនេះ ទ្រព្យសកម្មវិស័យធនាគារបានកើនឡើងយ៉ាងឆាប់រហ័សដល់ ១២៨ ទ្រីលានរៀល (ស្មើនឹងប្រមាណ ៣២ ប៊ីលានដុល្លារអាមេរិក) នាពេលបច្ចុប្បន្ន គឺបានកើនឡើងប្រមាណ ៨១ដង ហើយបើគិតជាកំណើនប្រចាំឆ្នាំវិញ គឺកើនឡើង២,៥ដង ក្នុងមួយឆ្នាំៗ។ ឥណទានវិស័យធនាគារចំពោះវិស័យឯកជនបានកើនឡើងដល់ ៧៧ ទ្រីលានរៀល (ស្មើនឹងប្រមាណ ១៨,៨ ប៊ីលានដុល្លារអាមេរិក) កើនឡើង ៩៣ដង ហើយប្រាក់បញ្ញើបានកើនឡើងដល់ ៦៧ ទ្រីលានរៀល (ស្មើនឹងប្រមាណ ១៦,៣ ប៊ីលានដុល្លារអាមេរិក) កើនឡើង៥២ដង។ ទន្ទឹមនេះ ទុនបម្រុងអន្តរជាតិដុលបានកើនឡើងពីកម្រិតតែប្រមាណ ៩៩ លានដុល្លារអាមេរិកនៅឆ្នាំ១៩៩៤ ដល់ ៨,២ ប៊ីលានដុល្លារអាមេរិក ដែលអាចធានាការនាំចូលបានប្រមាណ ៦ខែខ្ពស់ជាងកម្រិតអប្បបរមាគួរមាន (៣ខែ) គឺកើនឡើង៨០ដង ក្នុងរយៈពេល ២៣ឆ្នាំកន្លងមកនេះ ឬកើន៣,៥ដង ជាមធ្យមក្នុងមួយឆ្នាំៗ។ ក្នុងរយៈពេលពីរទសវត្សរ៍នេះដែរ កម្ពុជារក្សាបានស្ថិរភាពម៉ាក្រូសេដ្ឋកិច្ចល្អប្រសើរ ដែលអំណោយផលដល់ការរីកចម្រើនសកម្មភាពសេដ្ឋកិច្ច ដោយអត្រាអតិផរណាមានកម្រិតក្រោម ៥% ហើយតម្លៃប្រាក់រៀលមានស្ថិរភាពធៀបនឹងដុល្លារអាមេរិកក្នុងរង្វង់ ៤.០០០ រៀលក្នុង១ដុល្លារអាមេរិក។ ទន្ទឹមនេះ តាមការវាយតម្លៃរបស់មជ្ឈដ្ឋានអន្តរជាតិ ដូចជា មូលនិធិរូបិយវត្ថុអន្តរជាតិ ធនាគារពិភពលោកនិងភ្នាក់ងារចំណាត់ថ្នាក់ Moody's បានបង្ហាញថា ប្រព័ន្ធធនាគារកម្ពុជាទទួលបានជំនឿចិត្តខ្ពស់ពីវិស័យឯកជន និងជាប់ចំណាត់ថ្នាក់ទី៧លើភាពងាយស្រួលទទួលបានសេវាហិរញ្ញវត្ថុ

ហើយនារយៈពេលកន្លងមក ធនាគារជាតិនៃកម្ពុជាជាប់ចំណាត់ថ្នាក់ល្អក្នុងការរួមចំណែករក្សាស្ថិរភាពសេដ្ឋកិច្ចនិងអត្រាប្តូរប្រាក់ ដែលគាំទ្រដល់លំហូរចូលនៃការវិនិយោគផ្ទាល់បរទេសមកកម្ពុជា ទោះបីជាស្ថិតក្រោមកម្រិតដុល្លារូបនីយកម្មខ្ពស់ក៏ដោយ។

**ឯកឧត្តម លោកជំទាវ លោក លោកស្រី និងនាងកញ្ញា ជាទីមេត្រី!**

មុននឹងឈានចូលដំណាក់កាលអភិវឌ្ឍន៍រីកចម្រើនដូចសព្វថ្ងៃនេះ ប្រព័ន្ធធនាគារកម្ពុជាបានឆ្លងកាត់ដំណើរដ៏វែងឆ្ងាយពោរពេញដោយឧបសគ្គនិងការផ្លាស់ប្តូរជាច្រើនដំណាក់កាល។ ឆ្លៀតក្នុងឱកាសដ៏មហោឡារិកនេះ ខ្ញុំសូមជម្រាបជូនអង្គពិធីយើងអំពី៖ i/- ប្រវត្តិប្រព័ន្ធធនាគារកម្ពុជា ii/- ការរីកចម្រើនរបស់ប្រព័ន្ធធនាគារនារយៈពេល ៣៨ឆ្នាំចុងក្រោយ និង iii/- ទិសដៅនៃការអភិវឌ្ឍប្រព័ន្ធធនាគារក្នុងរយៈពេលវែង។

## I- ប្រវត្តិប្រព័ន្ធធនាគារកម្ពុជា

ការស្វែងយល់ពីប្រវត្តិនិងដកស្រង់បទពិសោធន៍ទាំងជោគជ័យនិងបរាជ័យពីអតីតកាលពិតជាមានការចាំបាច់ណាស់សម្រាប់មនុស្សជំនាន់ក្រោយ ជាពិសេស យុវជនដែលជាទំពាំងស្នងឫស្សី។ ការយល់ច្បាស់ពីបញ្ហាទាំងនេះ នឹងអាចឱ្យយើងអនុវត្តការងារ និងរៀបចំផែនការសកម្មភាពប្រកបដោយភាពត្រឹមត្រូវនិងគ្រប់ជ្រុងជ្រោយ សំដៅឈានទៅសម្រេចបានជោគជ័យនាពេលអនាគត។ ដូចសុភាសិតរបស់ទស្សនវិទូជនជាតិបារាំងនិងជាអ្នកនិពន្ធដ៏ល្បីលោក Victor Hugo បានពោលថា "La vieillesse bien comprise est l'âge de l'espérance" បានន័យថា នៅពេលដែលយើងយល់អំពីរឿងរ៉ាវប្រវត្តិសាស្ត្រទាំងឡាយបានច្បាស់លាស់ យើងនឹងអាចឈានដល់ដំណាក់កាលមួយ ដែលមានភាពចាស់ទុំក្នុងការអនុវត្តការងារ

ប្រកបដោយជោគជ័យ។ បើយើងយល់មិនច្បាស់ពីរឿងរ៉ាវដែលបានកើតឡើងនោះទេ យើងនឹងអាចប្រព្រឹត្តកំហុសដដែលៗ ឬដើរជាន់ដានចាស់ ដូចសុភាសិតមួយពោលថា "History repeats itself"។

### ១/- មុនសម័យអាណាព្យាបាលបារាំង

កម្ពុជាមានប្រវត្តិនៃការប្រើប្រាស់រូបិយវត្ថុយឺត បើធៀបនឹងប្រទេសមួយចំនួនក្នុងតំបន់និងលើពិភពលោក។ យោងតាមការសិក្សារបស់លោក Jean-Daniel Gardère បង្ហាញថា ភាពយឺតនៃការប្រើប្រាស់នេះអាចបណ្ដាលមកពី i/- សេដ្ឋកិច្ចកម្ពុជាពឹងផ្អែកច្រើនលើវិស័យកសិកម្ម ជាមួយនឹងទំនៀមទម្លាប់ដោះដូរទំនិញនឹងទំនិញ (Barter economy) និងការចែករំលែកឱ្យគ្នាទៅវិញទៅមក ii/- កម្ពុជាមិនមានការផលិតលោហធាតុមានតម្លៃច្រើនសម្រាប់បំពេញសេចក្ដីត្រូវការក្នុងការដោះដូរទេ និង iii/- រាជធានីខ្មែរបានផ្លាស់ទីតាំងបន្តិចម្ដងៗពីតំបន់ដែលធ្វើពាណិជ្ជកម្មអន្តរជាតិទៅតំបន់ដែលអំណោយផលដល់កសិកម្ម ដែលធ្វើឱ្យតម្រូវការរូបិយវត្ថុមានកម្រិតទាប។ តាមភ័ស្តុតាងកំណាយប្រវត្តិសាស្ត្រ បានបង្ហាញថា កម្ពុជាធ្លាប់ជាប្រទេសដែលបានប្រើប្រាស់រូបិយវត្ថុតិចតួចដែរ ដែលមានប្រភពមកពីអឺរ៉ុប អាមេរិកឡាទីន និងចិន ដែលបានចូលមកធ្វើពាណិជ្ជកម្មលើកំពង់ផែកម្ពុជា និងមកធ្វើទស្សនកិច្ចនៅកម្ពុជាចាប់តាំងពីសតវត្សរ៍ទី១មក។ កំណាយមួយដែលធ្វើឡើងនៅខេត្រតាកែវ ស្រុកអង្គរបូរី ក្បែរភ្នំដា បានរកឃើញកាសមាសមួយដែលសរសេរថា "**ព្យសានបុរៈ**" ហើយការរកឃើញនេះបានក្លាយជាសម្មតិកម្មថ្មីមួយដែលបង្ហាញថា កម្ពុជាបានផលិតកាសតំណាងរូបិយវត្ថុជាតិ តាំងពីសម័យព្យសានបុរៈមកម្ល៉េះ។ ខ្ញុំក៏សូមរំឭកផងដែរថា កាលពីខែកក្កដាថ្មីៗនេះ ប្រាសាទសម្បូរព្រៃគុកនៅស្រុកប្រាសាទសំបូរ ខេត្រកំពង់ធំ

ដែលបានកសាងឡើងនៅសតវត្សរ៍ទី៧ ជារាជធានីនៃល្វសានបុរៈ ត្រូវបានអង្គការ UNESCO ចុះបញ្ជីក្នុងបេតិកភណ្ឌពិភពលោក។ កាសប្រាក់ដែលគេសន្មតថាជារូបិយវត្ថុទីមួយរបស់កម្ពុជាគឺ **ប្រាក់ស្លឹង** (ជាមាសនិងប្រាក់សុទ្ធ) ដែលនៅផ្ទៃខាងមុខមានរូបនាគ និងត្រូវបានបោះផ្សាយដោយព្រះស្រីជេដ្ឋាធិរាជរាមាធិបតី នៅសតវត្សរ៍ទី១៦។ យោងតាមលោក Adhémard Leclère ដែលបានសរសេរក្នុងសៀវភៅ នៅឆ្នាំ១៩១៤ "ប្រវត្តិសាស្ត្រប្រទេសកម្ពុជា" នារជ្ជកាលព្រះស្រីជេដ្ឋា កម្ពុជាយើងបានបើកទូលាយពាណិជ្ជកម្មជាមួយបរទេស ដោយគេឃើញវត្តមានរបស់ជនជាតិអេស្ប៉ាញនិងព័រទុយហ្គាល់ បានចូលមកធ្វើពាណិជ្ជកម្មនៅកម្ពុជា។ សកម្មភាពសេដ្ឋកិច្ចនិងពាណិជ្ជកម្មបានរីកចម្រើនគួរឱ្យកត់សម្គាល់ ហើយប្រព័ន្ធពន្ធដារក៏ត្រូវបានរៀបចំផងដែរ។ ព្រះស្រីជេដ្ឋាបានបោះពុម្ពប្រាក់ស្លឹង ដើម្បីបង្ហាញពីអធិបតេយ្យភាពជាតិនិងធម្មានុរូបភាពរបស់ព្រះអង្គ។

បន្ទាប់មកនៅអំឡុងឆ្នាំ១៨៤៦ ព្រះបាទអង្គឌួង បានបោះពុម្ព "**ប្រាក់ប្រាសាទ**" ដែលនៅផ្ទៃម្ខាងមានរំលេចរូបហង្ស និងផ្ទៃម្ខាងទៀតមានរូបប្រាសាទអង្គរវត្ត ហើយនៅផ្នែកខាងក្រោមមានចារឹកអក្សរ "**ក្រុងកមពូជា**"។ នៅឆ្នាំ១៨៦០ ព្រះបាទនរោត្តមបានបោះពុម្ពរូបិយវត្ថុធ្វើពីសំរឹទ្ធ មានចារឹកអក្សរខ្មែរផងនិងអក្សរបារាំងផង។ រូបិយវត្ថុជាតិនេះខ្លះមានឯកតាជា **តៀន** និងខ្លះមានឯកតាជា **រៀល** ហើយនេះជាចំណុចចាប់ផ្តើមនៃឈ្មោះឯកតា **រៀល** របស់រូបិយវត្ថុខ្មែរយើងរហូតមកដល់បច្ចុប្បន្ន។

ទោះបីជាព្រះរាជាខ្មែរបានបោះផ្សាយរូបិយវត្ថុជាបន្តបន្ទាប់ក៏ដោយ ប៉ុន្តែរូបិយវត្ថុទាំងនោះមិនបានចរាចរទូលំទូលាយទេ ដោយសារបរិមាណផ្គត់ផ្គង់មានចំនួនតិច ប្រជាជន

មិនមានទម្លាប់ដោះដូរ ហើយរូបិយវត្ថុទាំងនេះត្រូវបានគេប្រើប្រាស់សម្រាប់តំណាងប្រទេស ដែលបង្ហាញពីអធិបតេយ្យភាព ជាជាងសម្រាប់ធ្វើជាមធ្យោបាយដោះដូរ។

**២/- សម័យអាណាព្យាបាលបារាំង (១៨៦៣ -១៩៥៣)**

ក្រោមការគ្រប់គ្រងរបស់អាណាព្យាបាលបារាំងរយៈពេល ៩០ឆ្នាំ ប្រទេសកម្ពុជា បានទទួលអំណោយផលពីការការពារផ្នែកព្រំដែន និងការធ្វើទំនើបកម្មសេដ្ឋកិច្ច។ នៅក្នុងឆ្នាំ១៨៧៥ ធនាគារឥណ្ឌូចិន (Banque de l'Indochine) របស់បារាំង បានទទួលសិទ្ធិពិសេសក្នុងការបោះផ្សាយរូបិយវត្ថុក្នុងតំបន់ឥណ្ឌូចិន គឺប្រទេសកម្ពុជា វៀតណាម និងឡាវ។ ៣ឆ្នាំក្រោយមក ធនាគារឥណ្ឌូចិនបានបោះពុម្ព "**ប្រាក់ព្យ៉ាស** (Piastres)" ជាកាសសម្រាប់ដាក់ឱ្យប្រទេសឥណ្ឌូចិនទាំងបីប្រើប្រាស់ ហើយចាប់ពីឆ្នាំ១៨៩១ ធនាគារឥណ្ឌូចិនបានបោះផ្សាយក្រដាសប្រាក់ព្យ៉ាស។ បន្ទាប់ពីការធ្វើកំណែទម្រង់ប្រព័ន្ធរូបិយវត្ថុឥណ្ឌូចិនជាបន្តបន្ទាប់ និងការទាមទារឱ្យបារាំងដកអាជ្ញាប័ណ្ណក្នុងការបោះពុម្ពពីធនាគារឥណ្ឌូចិនដោយប្រគល់អាជ្ញាប័ណ្ណនេះទៅឱ្យរដ្ឋាភិបាលនៃប្រទេសនីមួយៗនៅឥណ្ឌូចិនវិញ ចាប់ពីឆ្នាំ១៩៣០មក បារាំងបានឯកភាពនិងចេញច្បាប់ដកអាជ្ញាប័ណ្ណបោះពុម្ពរូបិយវត្ថុចេញពីធនាគារឥណ្ឌូចិន នៅខែកញ្ញា ឆ្នាំ១៩៤៥។ ការចរចាដើម្បីបង្កើតវិទ្យាស្ថានបោះផ្សាយប្រាក់សម្រាប់ឥណ្ឌូចិន ក៏ត្រូវបានធ្វើឡើងជាបន្តបន្ទាប់ ដូចជា មានកិច្ចព្រមព្រៀងនាខែវិច្ឆិកា ឆ្នាំ១៩៥០ នៅទីក្រុងប៉ូ និងការចុះហត្ថលេខាលើអនុសញ្ញាចតុភាគី នាខែធ្នូ ឆ្នាំ១៩៥០ នៅទីក្រុងប៉ារីស។ ទីបំផុត នៅឆ្នាំ១៩៥២ "**វិទ្យាស្ថានបោះពុម្ពនៃសមាគតរដ្ឋឥណ្ឌូចិន**" ត្រូវបានបង្កើតឡើងដោយមានទីស្នាក់ការកណ្តាលនៅទីក្រុងភ្នំពេញ និងបានបោះផ្សាយរូបិយវត្ថុសម្រាប់ប្រើប្រាស់ក្នុងប្រទេសទាំងបី។

## ៣/- សម័យសង្គមរាស្ត្រនិយម (១៩៥៣ - ១៩៧០)

បន្ទាប់ពីទទួលបានឯករាជ្យពីបារាំង សហភាពសមាគតរដ្ឋឥណ្ឌូចិន (L'Union des États Associés d'Indochine) បានជួបប្រជុំចតុភាគី (បារាំង កម្ពុជា វៀតណាម និងឡាវ) នៅទីក្រុងប៉ារីស ដើម្បីស្វែងរកដំណោះស្រាយក្នុងការទាមទារឯករាជ្យផ្នែករូបិយវត្ថុឱ្យប្រទេសសមាគតរដ្ឋនីមួយៗ។ ទីបំផុត បារាំងបានប្រគល់ឯករាជ្យផ្នែករូបិយវត្ថុទៅឱ្យប្រទេសទាំងបីនៅក្នុងកិច្ចប្រជុំចតុភាគីនៅថ្ងៃ២៩ ធ្នូ ១៩៥៤ គឺប្រទេសនីមួយៗមានធនាគារកណ្តាលនិងរូបិយវត្ថុជាតិរៀងខ្លួន ហើយធនាគារជាតិនៃកម្ពុជាដែលបានបង្កើតឡើងកាលពីថ្ងៃ២៣ ធ្នូ ១៩៥៤ បានចាប់ដំណើរការនៅខែឧសភា ១៩៥៥ និងបានបោះផ្សាយប្រាក់រៀលនៅខែកញ្ញានៅឆ្នាំដដែលនោះ។

ធនាគារជាតិនៃកម្ពុជា បានបម្រើយ៉ាងសកម្មដល់គោលនយោបាយកសាងជាតិនៃរបបសង្គមរាស្ត្រនិយម ហើយប្រាក់រៀលត្រូវបានពង្រឹងស្របតាមការវិវត្តរីកចម្រើននៃសេដ្ឋកិច្ចជាតិ។ នៅចុងឆ្នាំ១៩៦៣ ប្រព័ន្ធធនាគារកម្ពុជាត្រូវបានធ្វើកំណែទម្រង់ដោយធនាគារជាតិនៃកម្ពុជាបានប្រែក្លាយពីទម្រង់ជាស្ថាប័នពាក់កណ្តាលស្វយ័តទៅជាធនាគាររដ្ឋក្រោមទម្រង់ជាស្ថាប័នសាធារណៈ ដែលមានលក្ខណៈជាឧស្សាហកម្មផងនិងពាណិជ្ជកម្មផង។ ធនាគារឯកជនជាតិនិងបរទេសដែលកំពុងធ្វើប្រតិបត្តិការ ត្រូវបានប្រែក្លាយ ជាធនាគារដែលរដ្ឋកាន់កាប់។

## ៤/- របប លន់ នល់ (១៩៧០ - ១៩៧៥)

បន្ទាប់ពីកម្ពុជាមានសុខសន្តិភាពមួយរយៈ លន់ នល់ បានធ្វើរដ្ឋប្រហារទម្លាក់សម្តេច ព្រះនរោត្តម សីហនុ ពីអំណាចនៅថ្ងៃ១៨ មីនា ១៩៧០ និងបានប្តូររបបទៅជាសាធារណរដ្ឋខ្មែរ។ រដ្ឋប្រហារ លន់ នល់ នេះ បានធ្វើឱ្យប្រទេសជាតិធ្លាក់ក្នុងភ្លើងសង្គ្រាមអស្ថិរភាព និងចលាចល ហើយសេដ្ឋកិច្ចចាប់ផ្តើមធ្លាក់ក្នុងវិបត្តិយ៉ាងធ្ងន់ធ្ងរ។ សង្គ្រាមបានកើតឡើងនៅគ្រប់ទីកន្លែង ប្រទេសត្រូវបានកាត់ផ្តាច់ជាកង់ៗ ផលិតកម្មបានថយចុះដុនដាប ហើយប្រទេសទាំងមូលត្រូវពឹងផ្អែកលើជំនួយបរទេស។ ចំពោះការបោះផ្សាយរូបិយវត្ថុក្រដាសប្រាក់ក្នុងសម័យសង្គមរាស្ត្រនិយម ត្រូវបានអនុញ្ញាតឱ្យធ្វើចរាចរដដែល ហើយរបប លន់ នល់ បានបោះពុម្ពក្រដាសប្រាក់បន្ថែម។ ប្រព័ន្ធធនាគារបានធ្វើសេរីភាវូបនីយកម្មសារជាថ្មី ដើម្បីបង្កលក្ខណៈឱ្យធនាគារឯកជន អាចធ្វើសកម្មភាពទន្ទឹមនឹងធនាគាររដ្ឋទាំងឡាយ ក្រោមការណែនាំនិងត្រួតពិនិត្យរបស់ធនាគារជាតិនៃកម្ពុជា។ ទោះយ៉ាងណាឯកជនភាវូបនីយកម្មក្រុមហ៊ុនរដ្ឋ និងសេរីភាវូបនីយកម្មពាណិជ្ជកម្មបរទេសមានដំណើរការយឺត ហើយសង្គ្រាមស៊ីវិលនិងការចំណាយខ្ពស់ទៅលើថ្លៃដឹកជញ្ជូនបានធ្វើឱ្យរោងចក្រនិងក្រុមហ៊ុនបិទទ្វារជាបន្តបន្ទាប់។ ឱនភាពថវិការដ្ឋបានកើនឡើងយ៉ាងខ្លាំង ហើយដើម្បីបំពេញឱនភាពថវិការដ្ឋ ធនាគារកណ្តាលត្រូវបានបង្ខំឱ្យបោះពុម្ពប្រាក់បន្ថែមយ៉ាងច្រើនសន្ធឹកសន្ធាប់ ជាពិសេសសម្រាប់បើកប្រាក់ខែឱ្យមន្ត្រី-បុគ្គលិករដ្ឋ និងចំណាយផ្នែកយោធា។ ប្រាក់រៀលបានធ្លាក់ថ្លៃជាលំដាប់រហូតដល់កម្រិតមិនអាចគ្រប់គ្រងបាន។ ជាក់ស្តែង មាសដែលធ្លាប់តែមានតម្លៃ១តម្លឹង ៣.០០០រៀល បានកើនឡើងរហូតដល់ ៥០ម៉ឺនរៀល។

នាពេលនោះ អត្រាអតិផរណាបានកើនឡើងឥតឈប់ឈរពី ១២% នៅឆ្នាំ១៩៧០ ទៅ ៧១% នៅឆ្នាំ១៩៧២ និងរហូតដល់ ២២៨% នៅឆ្នាំ១៩៧៤។ កំណើនខ្ពស់នៃអតិផរណា និងការបាត់បង់តម្លៃរូបិយវត្ថុជាតិនាពេលនោះ បានចាប់ផ្តើមធ្វើឱ្យប្រជាជនបាត់បង់ជំនឿទុកចិត្តលើរូបិយវត្ថុជាតិជាលំដាប់។ ថ្លៃម្ហូបអាហារ ប្រេងឥន្ធនៈ និងរបស់របរនានាដែលតែងតែមានស្ថិរភាព បានប្រែប្រួលកើនឡើងមិនអាចគ្រប់គ្រងបាន។ ថ្លៃម្ហូបអាហារត្រូវបានកត់សម្គាល់ថា បានឡើងថ្លៃខ្លាំងជាងគេ ដោយសារមិនមានការផ្គត់ផ្គង់គ្រប់គ្រាន់ពីតាមបណ្តាខេត្តនានា។ ថ្លៃគុយទាវ១ចាន ដែលធ្លាប់តែមានតម្លៃត្រឹម ៥រៀល បានកើនដល់ ៥០០រៀល និងរហូតដល់ ១.០០០រៀល ក្នុង១ចាន នៅឆ្នាំ១៩៧៤។ ថ្លៃសាច់ជ្រូក កើនពី ១៥រៀល ក្នុង១គីឡូក្រាម ដល់ ៤.០០០រៀល ក្នុង១គីឡូក្រាម, ត្រកួន១បាច់ដែលធ្លាប់តែថ្លៃ ៥កាក់ (០,៥រៀល) ឬ១រៀល ឡើងដល់ ៥០០រៀល ហើយប្រេងសាំងបានកើនឡើងពី ៧រៀល ក្នុង១លីត្រ ដល់ ៧.០០០រៀល ក្នុង១លីត្រ។

## ៥/- ការលុបបំបាត់ចោលប្រព័ន្ធធនាគារនិងរូបិយវត្ថុ (១៩៧៥ -១៩៧៩)

របប លន់ នល់ ដែលបានកាន់អំណាចប្រមាណ ៥ឆ្នាំ ត្រូវបានផ្តួលរំលំ នៅថ្ងៃ១៧ មេសា ១៩៧៥។ របប ប៉ុល ពត បានចូលកាន់អំណាចបន្ត ហើយបានអនុវត្តនយោបាយប្រល័យពូជសាសន៍ ដោយបានកាប់សម្លាប់ប្រជាជនស្លូតត្រង់ និងបំផ្លាញហេដ្ឋារចនាសម្ព័ន្ធសេដ្ឋកិច្ចនិងសង្គម ដូចជា សាលារៀន មន្ទីរពេទ្យ ការិយាល័យរដ្ឋបាល អគារពាណិជ្ជកម្ម និងវត្តអារាម និងបានប្រែក្លាយប្រទេសកម្ពុជាទៅជាសង្គមទាសភាពបុព្វកាល "**ហូបរួម ដេករួម**"។ របប ប៉ុល ពត បានបំបាត់កម្មសិទ្ធិឯកជន ទីផ្សារ រូបិយវត្ថុ និងសិទ្ធិសេរីភាពគ្រប់បែបយ៉ាង សូម្បីតែសិទ្ធិជាមូលដ្ឋាន ដូចជា សិទ្ធិក្នុងការរស់នៅ រៀនសូត្រ ធ្វើការងារ រហូតដល់គ្មានសិទ្ធិ

ក្នុងការជ្រើសរើសគូស្រករដែលខ្លួនពេញចិត្ត គឺអង្គការជាអ្នករៀបចំដោយបង្ខំទាំងអស់។ ប្រជាជនបានក្លាយជាឧបករណ៍ដាច់ថ្លៃរបស់អង្គការ ដោយធ្វើការយ៉ាងវេទនាជាមួយនឹងអាហារតិចតួចបំផុត។ គួរបញ្ជាក់ថា ការលុបបំបាត់រូបិយវត្ថុមិនឱ្យចរាចរត្រូវបានពួក ប៉ុល ពត យល់ថា "លុយជាប្រភពនៃការជិះជាន់និងកេងប្រវ័ញ្ច"។ ដូច្នេះ ដើម្បីឱ្យសង្គមមួយស្មើភាពគ្នាទាំងអស់ គឺត្រូវតែបំបាត់លុយនិងទីផ្សារចោល។ ការបំបាត់ធនាគារកណ្តាលនិងរូបិយវត្ថុរបស់ ប៉ុល ពត បានរំលាយឫសគល់ទាំងស្រុងនូវយន្តការទីផ្សារនិងការអភិវឌ្ឍសេដ្ឋកិច្ចនិងសង្គមនៅកម្ពុជា និងធ្វើឱ្យប្រជាជនកម្ពុជាទាំងអស់ធ្លាក់ខ្លួនជាអ្នកក្រីក្រ។

## II- ការរីកចម្រើនប្រព័ន្ធធនាគាររយៈពេល ៣៨ឆ្នាំចុងក្រោយ

បទពិសោធន៍ដែលបានឆ្លងកាត់ដ៏វែងឆ្ងាយទាំងនេះបានផ្តល់នូវមេរៀនជាច្រើនដល់ប្រជាជនកម្ពុជាពីសង្គ្រាមនិងអស្ថិរភាពនយោបាយ ដែលបណ្តាលឱ្យធ្លាក់ចុះនៃវិស័យសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងតួនាទីដ៏សំខាន់របស់ធនាគារកណ្តាលនិងរូបិយវត្ថុជាតិនៅក្នុងការអភិវឌ្ឍសេដ្ឋកិច្ចនិងសង្គម។ រូបិយវត្ថុបានដើរតួនាទីសម្រួលដល់សកម្មភាពសេដ្ឋកិច្ចនិងបែងចែកកម្លាំងពលកម្មប្រកបដោយប្រសិទ្ធភាពនៅក្នុងសេដ្ឋកិច្ច តាមរយៈមុខងារទាំងបីរបស់រូបិយវត្ថុ គឺបង្កើតនូវឯកតាថ្លៃ មធ្យោបាយទូទាត់ និងសន្សំ។ ទន្ទឹមនេះ រូបិយវត្ថុក៏តំណាងឱ្យប្រទេសមួយផងដែរ ហើយជាកាតាលិករដ៏សំខាន់ក្នុងការពង្រឹងស្មារតីជាតិនិយម និងសាមគ្គីភាព ដោយសាររូបិយវត្ថុបានបង្កប់នូវខ្លឹមសាររំឭកពីកត្តាប្រវត្តិសាស្ត្រ ការរីកចម្រើននិងតថភាពសង្គម ដែលប្រជាជនក្នុងប្រទេសមួយជួបប្រទះជាមួយគ្នានិងផ្តល់តម្លៃជារួម។ អវត្តមានរូបិយវត្ថុ ត្រូវបានអ្នកប្រវត្តិសាស្ត្រចាត់ទុកថាជាកត្តាចម្បងមួយដែលបានធ្វើឱ្យអាណាចក្រខ្មែរសម័យអង្គរដែលបានរីកចម្រើនដល់កំពូលនិងរដ្ឋកាលបន្តបន្ទាប់ទៀត

កាលពីអតីតកាល ធ្លាក់ចុះដុនដាបជាលំដាប់ ដោយសាររដ្ឋមិនមានប្រភពហិរញ្ញវត្ថុគ្រប់គ្រាន់ ដើម្បីដំណើរការកិច្ចការប្រទេសសំខាន់ៗ ជាពិសេសកិច្ចការពារជាតិ ហើយប្រជាជនមិនអាចអភិវឌ្ឍសកម្មភាពសេដ្ឋកិច្ចទាំងក្នុងនិងក្រៅប្រទេសបាន ដែលជាប្រភពចំណូលដ៏សំខាន់របស់ប្រជាជននិងរដ្ឋ។ លើសពីនេះ អស្ថិរភាពតម្លៃរូបិយវត្ថុបានបណ្តាលឱ្យមានអស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច ដូចជាកំណើនអតិផរណា និងការថយចុះកំណើនសេដ្ឋកិច្ច។

**១/- ការស្តារប្រព័ន្ធធនាគារនិងរូបិយវត្ថុឡើងវិញ (១៩៧៩ - ១៩៨៦)**

ថ្ងៃ៧ មករា ១៩៧៩ ជាទិវាមហាជ័យជម្នះ ជាប្រវត្តិសាស្ត្រ និងជាថ្ងៃកំណើតទី២របស់ប្រជាជនកម្ពុជា ដែលកងទ័ពរណសិរ្សសាមគ្គីសង្គ្រោះជាតិកម្ពុជា ដឹកនាំដោយសម្តេចអគ្គមហាធម្មពោធិសាល ជា ស៊ីម សម្តេចអគ្គមហាពញាចក្រី ហេង សំរិន និងសម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន បានរំដោះប្រជាជននិងសង្គ្រោះប្រទេសជាតិមាតុភូមិ និងអ្វីៗទាំងអស់ចេញពីរបបប្រល័យពូជសាសន៍ ប៉ុល ពត។ ក្រោយថ្ងៃរំដោះរណសិរ្សសាមគ្គីសង្គ្រោះជាតិកម្ពុជា បានបំពេញតួនាទីជាអ្នកការពារអាយុជីវិតប្រជាជនផងទប់ស្កាត់ការវិលត្រឡប់នៃរបបកម្ពុជាប្រជាធិបតេយ្យផង ការពារទឹកដីផង ដោះស្រាយគ្រោះទុរភិក្សជូនប្រជាជនទូទាំងប្រទេសផង និងបង្កលក្ខណៈឱ្យប្រជាជនវិលត្រឡប់ទៅជួបជុំគ្រួសារញាតិមិត្ត និងវិលទៅស្រុកកំណើតផង ជាពិសេសបានរៀបចំកសាងរដ្ឋអំណាចប្រជាជនគ្រប់ផ្នែកនិងគ្រប់ថ្នាក់ ដើម្បីគ្រប់គ្រងទឹកដី។ ពេលនោះ សាធារណរដ្ឋប្រជាមានិតកម្ពុជាក៏បានចាប់បដិសន្ធិឡើង ហើយភារកិច្ចចម្បងរបស់រដ្ឋអំណាច គឺការការពារ និងកសាងមាតុភូមិកម្ពុជាឡើងវិញលើគ្រប់វិស័យ ដើម្បីបង្កលក្ខណៈឱ្យប្រជាជនរស់នៅក្នុងសុខសន្តិភាព និងការអភិវឌ្ឍ។

ក្នុងស្ថានភាពដែលប្រទេសជាតិទាំងមូលត្រូវខ្ទេចខ្ទាំក្លាយជាគំនរផេះផង់ ហេដ្ឋារចនាសម្ព័ន្ធសេដ្ឋកិច្ចនិងសង្គមត្រូវបានបំផ្លាញដល់ឫសគល់ ធនធានមនុស្សត្រូវបានបំផ្លាញ ហើយអ្នកដែលរស់រានមានជីវិតស្ថិតក្នុងស្ថានភាពបាក់កម្លាំងកាយនិងស្មារតី។ ដូច្នេះ ដើម្បីកសាងប្រទេសជាតិឡើងវិញលើគ្រប់វិស័យ រដ្ឋាភិបាលបានបង្កើតធនាគារកណ្តាល នៅថ្ងៃ១០ តុលា ១៩៧៩ ដែលនាពេលនោះមានឈ្មោះថា "ធនាគារជាតិនៃប្រជាជនកម្ពុជា"។

ធនាគារជាតិនៃប្រជាជនកម្ពុជាបានទទួលជំនួយបច្ចេកទេសនិងសម្ភារពីប្រទេសជាមិត្តរួមមាន វៀតណាមនិងអតីតសហភាពសូវៀត។ ក្នុងរយៈពេលត្រឹមតែ៦ខែប៉ុណ្ណោះក្រោយការបង្កើតធនាគារជាតិនៃប្រជាជនកម្ពុជា ប្រាក់រៀលថ្មីដែលតំណាងឱ្យអធិបតេយ្យភាពជាតិ ត្រូវបានបោះផ្សាយនិងដាក់ឱ្យចរាចរឡើងវិញ នៅថ្ងៃ២០ មីនា ១៩៨០ ដើម្បីធ្វើជាខ្នាតវាស់តម្លៃ មធ្យោបាយដោះដូរ និងជាឧបករណ៍សន្សំ សម្រាប់ឱ្យប្រជាពលរដ្ឋប្រើប្រាស់ក្នុងជីវភាពប្រចាំថ្ងៃ។ ការដាក់ឱ្យចរាចរប្រាក់រៀលឡើងវិញនេះ ត្រូវបានប្រជាពលរដ្ឋទូទាំងប្រទេសកម្ពុជាអបអរសាទរនិងស្វាគមន៍យ៉ាងខ្លាំង ហើយគឺជាព្រឹត្តិការណ៍ជោគជ័យរបស់រដ្ឋាភិបាលក្នុងការអនុវត្តគោលនយោបាយសេដ្ឋកិច្ចផងដែរ។

ការបោះប្រាក់រៀលនិងការដាក់ឱ្យចរាចរឡើងវិញ បានជួយរួមចំណែកធ្វើឱ្យសកម្មភាពសេដ្ឋកិច្ចជាតិរស់ឡើងវិញលើគ្រប់វិស័យ និងបានអនុញ្ញាតឱ្យពាណិជ្ជកម្មរដ្ឋចាប់ផ្តើមធ្វើសកម្មភាពក្នុងលក្ខណៈជាអាជីវកម្មចំណេញ-ខាត ធ្វើឱ្យពាណិជ្ជកម្មឯកជននិងទីផ្សារមានសកម្មភាពជាប្រក្រតីនិងរីកចម្រើនជាលំដាប់។ ប្រព័ន្ធថវិការដ្ឋនិងសេវាធនាគាររដ្ឋក៏ត្រូវបានរស់រានមានជីវិតនិងមានសកម្មភាពជាថ្មីឡើងវិញ។ ក្នុងអំឡុងពេលនោះ ប្រព័ន្ធធនាគារ

កម្ពុជាមានទម្រង់ជាប្រព័ន្ធមួយថ្នាក់ (Mono-banking system) ដែលធនាគារជាតិនៃប្រជាជនកម្ពុជាបានដើរតួនាទីសំខាន់ៗបី គឺជាអាជ្ញាធររូបិយវត្ថុ ជាធនាគារពាណិជ្ជ និងជារតនាគារជាតិ។

## ២/- ដំណើរការកំណែទម្រង់សេដ្ឋកិច្ច (១៩៨៦ - ១៩៩៣)

ចាប់ពីឆ្នាំ១៩៨៦ សភាពការណ៍សេដ្ឋកិច្ចកម្ពុជាមានការវិវត្តប្រែប្រួលជាវិជ្ជមានគួរឱ្យកត់សម្គាល់ ដោយរដ្ឋាភិបាលបានធ្វើកំណែទម្រង់សេដ្ឋកិច្ចពីរបបសេដ្ឋកិច្ចផែនការប្រមូលផ្តុំឱ្យទៅជាយន្តការសេដ្ឋកិច្ចផែនការផ្សារភ្ជាប់នឹងទីផ្សារជាបណ្តើរៗ ដើម្បីឈានទៅរកសេដ្ឋកិច្ចទីផ្សារសេរី។ នាពេលនោះ រដ្ឋបានទទួលស្គាល់កម្មសិទ្ធិឯកជន ដូចជាដីធ្លី មធ្យោបាយផលិតកម្មនិងកសិកម្ម, បានធ្វើឯកជនភាវូបនីយកម្មលើសហគ្រាសរដ្ឋ ដោយបានកាត់បន្ថយតួនាទីរបស់កម្មសិទ្ធិរដ្ឋ, ការបញ្ចប់ភាពផ្តាច់មុខរបស់រដ្ឋលើការធ្វើពាណិជ្ជកម្មក្រៅប្រទេស ដោយបានប្តូរពីតួនាទីផ្តាច់មុខក្នុងការនាំចេញ-នាំចូល មកគ្រប់គ្រងនិងចាត់ចែងពាណិជ្ជកម្មក្រៅប្រទេសវិញ និងការអនុម័តច្បាប់ស្តីពីការវិនិយោគបរទេស ដែលបើកផ្លូវឱ្យវិនិយោគិនបរទេសមកវិនិយោគនៅកម្ពុជា។

ទន្ទឹមនឹងកំណែទម្រង់សេដ្ឋកិច្ចនេះ ប្រព័ន្ធធនាគារក៏បានចាប់ផ្តើមធ្វើកំណែទម្រង់ផងដែរ ហើយអគារស្នាក់ការធនាគារកណ្តាលត្រូវបានកសាងឡើងវិញនៅឆ្នាំ១៩៩០។ នៅឆ្នាំ១៩៩១ ដើម្បីបម្រើសេវាផ្ទេរប្រាក់ ដាក់ប្រាក់ និងបើកប្រាក់ខែ សម្រាប់ការចំណាយរបស់ប្រតិបត្តិការអាជ្ញាធរបណ្តោះអាសន្នរបស់អង្គការសហប្រជាជាតិនៅកម្ពុជា (ដែលហៅកាត់ថា UNTAC) រដ្ឋាភិបាលបានអនុញ្ញាតឱ្យធនាគារពាណិជ្ជបរទេសមួយ (CCB) មកបើកសាខានៅកម្ពុជា។ ដោយមានវត្តមានធនាគារឯកជន ប៉ុន្តែកម្ពុជាមិនទាន់មានច្បាប់

សម្រាប់គ្រប់គ្រង ហេតុដូច្នេះ នៅឆ្នាំ១៩៩២ រដ្ឋាភិបាលបានសម្រេចដាក់ឱ្យប្រើប្រាស់ច្បាប់ចំនួនពីរ។ ទី១គឺ ច្បាប់ស្ដីពីការកែប្រែឈ្មោះអង្គការចាត់តាំងនិងភារកិច្ចរបស់ធនាគារជាតិនៃប្រជាជនកម្ពុជា ប្ដូរឈ្មោះធនាគារជាតិនៃប្រជាជនកម្ពុជាទៅជា"**ធនាគារជាតិនៃកម្ពុជា**" ដូចសម័យសង្គមរាស្ត្រនិយមវិញ និងផ្ដល់សិទ្ធិឱ្យធនាគារជាតិនៃកម្ពុជាគ្រប់គ្រងលើគ្រឹះស្ថានធនាគារ។ ទី២គឺ ច្បាប់ស្ដីពីការគ្រប់គ្រងស្ថាប័នរូបិយវត្ថុ (ដែលកាលនោះសំដៅលើគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ) ដែលបានចែងពីដំណើរការសុំការអនុញ្ញាតធ្វើអាជីវកម្ម និងការប្រព្រឹត្តទៅរបស់ស្ថាប័នរូបិយវត្ថុ ព្រមទាំងបទប្បញ្ញត្តិនានា។ ដើម្បីពង្រឹងការត្រួតពិនិត្យធនាគារនិងមុខងារនានារបស់ធនាគារកណ្ដាល ធនាគារជាតិនៃកម្ពុជាបានបង្កើតនាយកដ្ឋានត្រួតពិនិត្យ និងនាយកដ្ឋានចម្បងៗមួយចំនួនទៀតផងដែរ។ នាពេលនោះ ធនាគារជាតិនៃកម្ពុជាបានចាប់ផ្ដើមកំណត់ដើមទុនអប្បបរមារបស់គ្រឹះស្ថានធនាគារ ក្នុងចំនួន ១០ ប៊ីលានរៀល (ស្មើនឹងប្រមាណ ៥ លានដុល្លារអាមេរិក)។ ទោះយ៉ាងណា ធនាគារជាតិនៃកម្ពុជានាពេលនោះមិនទាន់មានធនធានមនុស្សគ្រប់គ្រាន់ និងវិធីសាស្ត្រត្រួតពិនិត្យដែលមានស្តង់ដារអន្តរជាតិដូចសព្វថ្ងៃទេ។ ទាំងនេះគឺជាអាទិភាពចម្បងរបស់ធនាគារកណ្ដាល ដោយសារតែចំនួនគ្រឹះស្ថានធនាគារចាប់ផ្ដើមកើនឡើងជាបន្តបន្ទាប់។

## ៨/- ការកសាងសេដ្ឋកិច្ចទីផ្សារនិងការបើកទូលាយប្រព័ន្ធធនាគារ (១៩៩៣-១៩៩៨)

ការអនុវត្តនយោបាយបង្រួបបង្រួមជាតិ ការបោះឆ្នោតសកលទូទាំងប្រទេសដែលរៀបចំឡើងដោយអង្គការសហប្រជាជាតិ បាននាំមកនូវបរិយាកាសថ្មីដល់ប្រជាជាតិទាំងមូល។ កម្ពុជាមានរដ្ឋាភិបាលថ្មី ហើយបានបង្កើតរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រទី២។ កម្ពុជាបានបើកទ្វារទូលំទូលាយទៅកាន់ពិភពលោក ទទួលការឧបត្ថម្ភគាំទ្រពីសហគមន៍អន្តរជាតិ

អនុវត្តរបបសេដ្ឋកិច្ចទីផ្សារ អនុវត្តលទ្ធិប្រជាធិបតេយ្យសេរីពហុបក្ស កសាងនីតិរដ្ឋ គោរពសិទ្ធិមនុស្ស ព្រមទាំងទទួលការវិលមកកសាងសង្គមជាតិវិញនៃប្រជាជនកម្ពុជាគ្រប់ទិសទី និងគ្រប់និន្នាការនយោបាយ។

ការរីកចម្រើនប្រព័ន្ធធនាគារ ក៏បានដើរស្របនឹងដំណើរការអភិវឌ្ឍសេដ្ឋកិច្ចដែរ។ កំណើននៃប្រតិបត្តិការរបស់គ្រឹះស្ថានធនាគារ បានតម្រូវឱ្យធនាគារជាតិនៃកម្ពុជាពង្រឹងការគ្រប់គ្រងរបស់ខ្លួនជាលំដាប់ ពិសេសការត្រួតពិនិត្យគ្រឹះស្ថានធនាគារ។ នៅឆ្នាំ១៩៩៦ ច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃធនាគារជាតិនៃកម្ពុជា ត្រូវបានអនុម័តដោយរដ្ឋសភា ដើម្បីពង្រឹងប្រសិទ្ធភាពប្រតិបត្តិការ និងតួនាទីរបស់ធនាគារជាតិនៃកម្ពុជាក្នុងការដឹកនាំគោលនយោបាយរូបិយវត្ថុ និងជាអាជ្ញាធរអាណាព្យាបាលលើប្រព័ន្ធធនាគារទាំងមូល សំដៅរក្សាស្ថិរភាពថ្លៃនិងអភិវឌ្ឍវិស័យធនាគារ ឆ្ពោះទៅពង្រឹងស្ថិរភាពម៉ាក្រូសេដ្ឋកិច្ចនិងការអភិវឌ្ឍសេដ្ឋកិច្ចជាតិ។ ផ្អែកលើច្បាប់នេះហើយ ដែលប្រព័ន្ធធនាគារកម្ពុជាបានប្រែក្លាយពីធនាគារមួយថ្នាក់ទៅប្រព័ន្ធធនាគារពីរថ្នាក់ (two-tier banking system) ដែលក្នុងនោះធនាគារជាតិនៃកម្ពុជាបានបញ្ឈប់ការបើកនិងរក្សាគណនីឱ្យសាធារណជនទាំងស្រុង គឺអាចបើកគណនីបានសម្រាប់ជូនរដ្ឋ គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ និងស្ថាប័នហិរញ្ញវត្ថុអន្តរជាតិប៉ុណ្ណោះ និងផ្តោតតួនាទីជាអាជ្ញាធរអាណាព្យាបាលលើវិស័យធនាគារ និងទុកតួនាទីផ្តល់សេវាហិរញ្ញវត្ថុដល់សាធារណជនជូនគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ។ បន្ទាប់មក ដើម្បីជាមូលដ្ឋានគតិយុត្តក្នុងការគ្រប់គ្រងទីផ្សារប្តូរប្រាក់ ច្បាប់ស្តីពីការគ្រប់គ្រងការប្តូរប្រាក់ ត្រូវបានអនុម័តនៅឆ្នាំ១៩៩៧។

នៅឆ្នាំ១៩៩៨ ក្រោមនយោបាយឈ្នះ-ឈ្នះ របស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា អង្គការចាត់តាំងរបស់ ប៉ុល ពត ទាំង

ផ្នែកនយោបាយនិងយោធា ត្រូវបានរំលាយទាំងស្រុង ហើយកម្ពុជាទទួលបានសន្តិភាព និងឯកភាពទឹកដីពេញលេញ ១០០%។ នេះគឺជាជោគជ័យមួយដ៏អស្ចារ្យដែលមិនធ្លាប់មាន ក្នុងប្រវត្តិសាស្ត្រកម្ពុជា តាំងពីក្រោយសម័យអង្គរមក ដែលនៅលើទឹកដីកម្ពុជាទាំងមូល មានរដ្ឋាភិបាលតែមួយ រដ្ឋធម្មនុញ្ញតែមួយ និងកងទ័ពជាតិតែមួយ។

**ក/- ការអភិវឌ្ឍនិងការធ្វើទំនើបកម្មប្រព័ន្ធធនាគារ (១៩៩៩-២០១៧)**

ក្រោយពេលដែលវិបត្តិហិរញ្ញវត្ថុអាស៊ីបានផ្ទុះឡើងនៅឆ្នាំ១៩៩៧-៩៨ ឥទ្ធិពលនៃវិបត្តិបានរីករាលដាលដល់ប្រទេសនៅតំបន់អាស៊ី។ ដើម្បីពង្រឹងភាពធន់និងអភិវឌ្ឍប្រព័ន្ធធនាគារឱ្យបានរឹងមាំ កម្ពុជាបានអនុម័តច្បាប់ស្តីពីគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ នៅថ្ងៃ១៨ វិច្ឆិកា ១៩៩៩ សម្រាប់គ្រប់គ្រងសកម្មភាពគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុដែលធ្វើប្រតិបត្តិការនៅកម្ពុជា។ ទន្ទឹមនេះ ធនាគារជាតិនៃកម្ពុជាបានដាក់ចេញនូវកម្មវិធីកំណែ-ទម្រង់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុនៅឆ្នាំ១៩៩៩-២០០០។ នេះគឺជាកំណែទម្រង់ទី១ដ៏មានសារៈសំខាន់ ដែលបានពង្រឹងស្ថិរភាពនិងការអភិវឌ្ឍវិស័យធនាគារដល់សព្វថ្ងៃ។ នៅអំឡុងឆ្នាំ២០០០ ចំនួនគ្រឹះស្ថានធនាគារមានរហូតដល់ ៣០ ដែលក្នុងនោះមានទាំងគ្រឹះស្ថានធនាគារដែលមានបទពិសោធន៍និងជំនាញតាមស្តង់ដារអន្តរជាតិ និងមានទាំងគ្រឹះស្ថានដែលមិនមានគុណវុឌ្ឍិគ្រប់គ្រាន់។ ការធ្វើកំណែទម្រង់នេះបានតម្រូវឱ្យគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុទាំងអស់ ស្នើសុំអាជ្ញាប័ណ្ណឡើងវិញជាមួយនឹងការបំពេញដើមទុនអប្បបរមាខ្ពស់ជាងមុន គឺមានចំនួន ៥០ ប៊ីលានរៀល (ស្មើនឹងប្រមាណ ១២,៥ លានដុល្លារអាមេរិក) និងតម្រូវឱ្យគ្រឹះស្ថានទាំងនោះរៀបចំនិងពង្រឹងរចនាសម្ព័ន្ធគ្រប់គ្រងផ្ទៃក្នុង ដើម្បីកាត់បន្ថយនូវហានិភ័យផ្សេងៗ។

ដំណើរការកំណែទម្រង់បានប្រព្រឹត្តទៅដោយជោគជ័យ។ ក្រោយពីការធ្វើកំណែ-ទម្រង់ មានគ្រឹះស្ថានធនាគារ ១៥ បានបិទទ្វារ ដែលក្នុងនោះមានគ្រឹះស្ថាន ១០ ស្ម័គ្រចិត្ត

ជម្រះបញ្ជីដោយមិនមានដើមទុនគ្រប់គ្រាន់ និងមានគ្រឹះស្ថានធនាគារ ៥ទៀត ត្រូវបង្ខំឱ្យជម្រះបញ្ជីនិងសងអ្នកដាក់ប្រាក់បញ្ញើ។ ចាប់ពីឆ្នាំ២០០០មក គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុទាំងអស់បានទទួលអាជ្ញាប័ណ្ណថ្មី ដែលក្នុងនោះធនាគារពាណិជ្ជកម្មក្រៅប្រទេស (FTB) ដែលធ្លាប់ជាផ្នែកមួយនៃធនាគារជាតិនៃកម្ពុជា ក៏ត្រូវបានធ្វើឯកជនភាវូបនីយកម្មនៅចុងឆ្នាំ២០០០ និងបានទទួលអាជ្ញាប័ណ្ណនៅឆ្នាំ២០០១។

ក្រៅពីការពង្រឹងគ្រឹះស្ថានធនាគារ ប្រព័ន្ធធនាគារក៏មិនទាន់មានឯកភាពគ្នាលើការរៀបចំរបាយការណ៍ ជាពិសេសប្លង់គណនី (chart of account) ដោយសារគ្រឹះស្ថានធនាគារនីមួយៗមានទម្រង់ប្លង់គណនីខុសៗគ្នា។ ភាពខុសគ្នានេះបានបង្កនូវការលំបាកដល់ការត្រួតពិនិត្យ និងការវាយតម្លៃស្ថានភាពវិស័យធនាគារទាំងមូល។ ដូច្នេះ ធនាគារជាតិនៃកម្ពុជាបានរៀបចំឡើងវិញនូវប្លង់គណនីតែមួយ និងទម្រង់របាយការណ៍ឱ្យមានសង្គតិភាពក្នុងវិស័យធនាគារ ហើយការងារនេះត្រូវបានបញ្ចប់ដោយជោគជ័យនៅឆ្នាំ២០០៥។ បន្ទាប់មក ធនាគារជាតិនៃកម្ពុជាបានពង្រឹងការត្រួតពិនិត្យឱ្យស្របតាមស្តង់ដារអន្តរជាតិ និងគោលការណ៍ត្រួតពិនិត្យទីក្រុងបាសែល ដោយបានបង្កើតឱ្យមានការត្រួតពិនិត្យលើឯកសារនិងដល់ទីកន្លែង។ ហើយនៅឆ្នាំ២០១១ ធនាគារជាតិនៃកម្ពុជាបានពង្រឹងរចនា-សម្ព័ន្ធនិងការគ្រប់គ្រងប្រតិបត្តិការរបស់ខ្លួន ដោយបានប្រែក្លាយនាយកដ្ឋានត្រួតពិនិត្យទៅជាអគ្គនាយកដ្ឋានត្រួតពិនិត្យ និងបានពង្រឹងការងារប្រតិបត្តិការធនាគារកណ្តាលឱ្យកាន់តែរឹងមាំ ក្រោមអគ្គនាយកដ្ឋានបច្ចេកទេស និងអគ្គនាយកដ្ឋានចម្បងដទៃទៀតដែលមានស្រាប់។

ជារួម វិស័យធនាគារបានវិវត្តយ៉ាងឆាប់រហ័សចាប់ពីឆ្នាំ២០០០មក ដែលឆ្លុះបញ្ចាំងតាមរយៈការកើនឡើងនៃទំហំប្រតិបត្តិការនិងវិសាលភាព ទន្ទឹមនឹងការបង្កើនដើមទុនអប្ប-បរមារបស់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុជាបន្តបន្ទាប់ ស្របតាមការរីកចម្រើនរបស់វិស័យធនាគារ ដូចជា នៅឆ្នាំ២០០៨ ដើមទុនអប្បបរមារបស់គ្រឹះស្ថានធនាគារត្រូវបាន

ដំឡើងដល់ ១៥០ ប៊ីលានរៀល (ស្មើនឹងប្រមាណ ៣៧,៥ លានដុល្លារអាមេរិក) បន្ទាប់មកបាន ដំឡើងថែមទៀតដល់ ៣០០ ប៊ីលានរៀល (ស្មើនឹងប្រមាណ ៧៥ លានដុល្លារអាមេរិក) នៅឆ្នាំ២០១៦កន្លងមកនេះ។ ការបង្កើនដើមទុនទាំងនេះបានធ្វើឱ្យមូលដ្ឋានដើមទុន របស់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុកើនឡើង និងពង្រឹងភាពរឹងមាំនៃប្រព័ន្ធធនាគារ កម្ពុជាបន្ថែមទៀត។ គួរកត់សម្គាល់ផងដែរថា នៅចុងឆ្នាំ២០០១ ប្រព័ន្ធធនាគារមានចំនួន ២១ និងបានថយចុះមកត្រឹម ១៧ ចាប់ពីឆ្នាំ២០០២ ដល់ ២០០៤ ដោយមានទ្រព្យសកម្ម ត្រឹមតែប្រមាណ ៣ ទ្រីលានរៀល (ស្មើនឹងប្រមាណ ៧៥០ លានដុល្លារអាមេរិក) ប៉ុណ្ណោះ នាពេលនោះ។ នៅដំណាច់ឆ្នាំ២០០៥ ប្រព័ន្ធធនាគារមានធនាគារពាណិជ្ជចំនួន ១៥ ធនាគារឯកទេស ៤ និង គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ១៦ ដោយទ្រព្យសកម្មគ្រឹះស្ថានធនាគារមាន ចំនួន ៥,៥ ទ្រីលានរៀល (ស្មើនឹងប្រមាណ ១,៤ ប៊ីលានដុល្លារអាមេរិក) កើនឡើងជិតទ្វេដង ហើយទ្រព្យសកម្មគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុមានចំនួន ២៤៧ ប៊ីលានរៀល (ស្មើនឹងប្រមាណ ៦១,៧ លានដុល្លារអាមេរិក)។ នៅដើមឆ្នាំ២០១០ ចំនួនគ្រឹះស្ថានធនាគារពាណិជ្ជបានកើន ដល់ ២៧ ធនាគារឯកទេស ៦ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុទទួលប្រាក់បញ្ញើ ៨ និងគ្រឹះស្ថាន មីក្រូហិរញ្ញវត្ថុមិនទទួលប្រាក់បញ្ញើ ១២ ដោយទ្រព្យសកម្មគ្រឹះស្ថានធនាគារមានចំនួន ២០,៨ ទ្រីលានរៀល (ស្មើនឹងប្រមាណ ៥,២ ប៊ីលានដុល្លារអាមេរិក) កើនឡើងជិត៤ដង ហើយ ទ្រព្យសកម្មគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុមានចំនួន ១,៥ ទ្រីលានរៀល (ស្មើនឹងប្រមាណ ៣៧៥ លានដុល្លារអាមេរិក) កើនឡើងជិត៦ដង។

នៅចុងខែកក្កដា ឆ្នាំ២០១៧ នេះ ចំនួនគ្រឹះស្ថានធនាគារបានកើនឡើងដល់ ៣៩ ធនាគារឯកទេស ១៥ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុទទួលប្រាក់បញ្ញើ ៧ និងគ្រឹះស្ថានមីក្រូ-

ហិរញ្ញវត្ថុមិនទទួលប្រាក់បញ្ញើកើនដល់ ៦៦ ហើយទ្រព្យសកម្មគ្រឹះស្ថានធនាគារមានចំនួន ១០៩,២ ទ្រីលានរៀល (ស្មើនឹងប្រមាណ ២៧,៣ ប៊ីលានដុល្លារអាមេរិក) កើនឡើងជិត៥ដង ហើយទ្រព្យសកម្មគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុមានចំនួន ១៨,៨ ប៊ីលានរៀល (ស្មើនឹងប្រមាណ ៤,៧ ប៊ីលានដុល្លារអាមេរិក) កើនឡើងជិត១០ដង។ សរុបមក ទ្រព្យសកម្មវិស័យធនាគារ (រួមមានគ្រឹះស្ថានធនាគារនិងមីក្រូហិរញ្ញវត្ថុ) នៅឆមាសទី១ ឆ្នាំ២០១៧ បានកើនឡើង ៩១ដង បើធៀបនឹងឆ្នាំ២០០១, កើន២៣ដង បើធៀបនឹងឆ្នាំ២០០៥ និងកើនជិត៥ដង ធៀបនឹងឆ្នាំ២០១០មក។

ម្យ៉ាងទៀត នៅជាងមួយទសវត្សរ៍ចុងក្រោយនេះ ធនាគារជាតិនៃកម្ពុជាក៏បានធ្វើទំនើបកម្មប្រព័ន្ធទូទាត់ជាលំដាប់ ដោយផ្អែកលើបច្ចេកវិទ្យាអេឡិចត្រូនិក ដើម្បីកាត់បន្ថយចំណាយប្រតិបត្តិការ ព្រមទាំងទទួលបានការទូទាត់ឆាប់រហ័សនិងសុវត្ថិភាព។ ការសិក្សាទៅលើឥទ្ធិពលនៃការប្រើប្រាស់កាតអេឡិចត្រូនិក បានបង្ហាញថា ការប្រើប្រាស់កាន់តែច្រើននៃការទូទាត់អេឡិចត្រូនិកបានបង្កើនការប្រើប្រាស់ (ជាមធ្យមប្រមាណ 0,៧%) ព្រមទាំងបង្កើនកំណើនផលិតផលក្នុងស្រុកសរុប (ជាមធ្យមប្រមាណ 0,១៧%)។ ប្រព័ន្ធទូទាត់អេឡិចត្រូនិកដែលបាននិងកំពុងអភិវឌ្ឍទាំងនេះ រួមមាន៖

- ប្រព័ន្ធទូទាត់រាយអេឡិចត្រូនិកជារូបិយវត្ថុជាតិ (FAST) ដែលអនុញ្ញាតឱ្យអ្នកត្រូវគេទូទាត់អាចទទួលបានមូលនិធិភ្លាមក្នុងកម្រៃសេវាទាបសមរម្យក្រោយពីការទូទាត់។

- ការដាក់ឱ្យប្រើប្រាស់ប្រព័ន្ធ "Cambodian Shared Switch" ដែលអនុញ្ញាតឱ្យអ្នកដែលកាន់ប័ណ្ណ ATM របស់ធនាគារណាមួយ អាចដកប្រាក់នៅម៉ាស៊ីន ATM របស់ធនាគារដទៃផ្សេងទៀតបាន និង
- កំពុងអភិវឌ្ឍប្រព័ន្ធទូទាត់ដុលភ្លាមៗ ដើម្បីឆ្លើយតបទៅនឹងការអភិវឌ្ឍក្នុងប្រទេស និងតំបន់ ជាពិសេសការធ្វើសមាហរណកម្មប្រព័ន្ធទូទាត់ក្នុងតំបន់អាស៊ាន។

ដោយឡែកក្នុងរយៈពេល១៨ឆ្នាំចុងក្រោយនេះ ធនាគារជាតិនៃកម្ពុជាក៏បានបន្តខិតខំប្រឹងប្រែងក្នុងការពង្រឹងការប្រើប្រាស់ប្រាក់រៀល តាមរយៈការដាក់ចេញនូវវិធានការផ្អែកលើយន្តការទីផ្សារនិងដោយសន្សឹមៗ។ ជាលទ្ធផល នៅក្នុងអំឡុងពេលនេះ ចំនួនប្រាក់រៀលក្នុងចរាចរបានកើនឡើង១៦ដង ដល់ ៨,៧ ប៊ីលានរៀល (ស្មើនឹងប្រមាណ ២,២ ប៊ីលានដុល្លារអាមេរិក) ហើយប្រាក់បញ្ញើជារៀលកើនជាង៩ដង ដល់ ៣,៨ ប៊ីលានរៀល (ស្មើនឹងប្រមាណ ៩៣៨,៥ លានដុល្លារអាមេរិក)។ បើធៀបនឹងឆ្នាំ១៩៩៣ ចំនួនប្រាក់រៀលក្នុងចរាចរនិងប្រាក់បញ្ញើជារៀលសរុបបានកើនឡើង៣០ដង ឬកើនជាមធ្យម១,៣ដង ក្នុងមួយឆ្នាំៗ។ ទន្ទឹមនឹងកំណើនតម្រូវការប្រាក់រៀល ធនាគារជាតិនៃកម្ពុជាក៏បានបោះផ្សាយមូលបត្រអាចជួញដូរបាន (Negotiable Certificate of Deposit -NCD) នៅឆ្នាំ២០១៣ និងដាក់ឱ្យដំណើរការប្រតិបត្តិការផ្តល់សន្ទនីយភាពដោយមានការធានា (Liquidity Providing Collateralized Operation -LPCO) នៅឆ្នាំ២០១៦។ ការបង្កើត NCD មានគោលបំណងផ្តល់ជាឧបករណ៍បំណុលរយៈពេលខ្លីជាប្រាក់ដុល្លារអាមេរិកនិងប្រាក់រៀល ដើម្បីសម្រួលដល់ការគ្រប់គ្រងសន្ទនីយភាពរបស់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ, សម្រាប់ធ្វើជាវត្ថុធានាក្នុងទីផ្សារអន្តរធនាគារ និងដើម្បីឱ្យធនាគារជាតិនៃកម្ពុជាអាចស្រូបយកសន្ទនីយភាពលើសពីវិស័យធនាគារ។

ចំណែកឯប្រតិបត្តិការ LPCO កន្លងមកបានផ្តល់ប្រាក់កម្ចីជាប្រាក់រៀល ដែលធនាគារជាតិនៃកម្ពុជាទទួលបានពីគ្រឹះស្ថានដែលមានសន្ទនីយភាពលើស តាមរយៈការបោះផ្សាយ NCD។ ប្រតិបត្តិការ LPCO បានរួមចំណែកបន្ទាបអត្រាការប្រាក់កម្ចីជារៀល និងបង្កើនលទ្ធភាពឱ្យគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុផ្តល់ឥណទានជារៀល ជាពិសេស ដើម្បីគាំទ្រការអភិវឌ្ឍវិស័យកសិកម្ម ដែលកំពុងប្រើប្រាស់ប្រាក់រៀលយ៉ាងទូលំទូលាយ ស្របតាមគោលនយោបាយរបស់រាជរដ្ឋាភិបាល។

ការពង្រឹងការប្រើប្រាស់ប្រាក់រៀល និងការអភិវឌ្ឍទីផ្សារអន្តរធនាគារ បានរួមចំណែកពង្រឹងប្រសិទ្ធភាពគោលនយោបាយរូបិយវត្ថុជាបន្តបន្ទាប់។ ទោះយ៉ាងណា ការអនុវត្តគោលនយោបាយរូបិយវត្ថុនៅតែមានកម្រិត ដោយសារបញ្ហាដុល្លារូបនីយកម្មខ្ពស់។ ក្នុងស្ថានភាពនេះ ធនាគារជាតិនៃកម្ពុជាបានពឹងផ្អែកលើគោលនយោបាយអត្រាប្តូរប្រាក់សម្រាប់រក្សាស្ថិរភាពថ្លៃ។ អត្រាប្តូរប្រាក់ត្រូវបានរក្សាឱ្យមានស្ថិរភាពល្អប្រសើរក្នុងរយៈពេល ១៨ឆ្នាំចុងក្រោយនេះ ដោយមានអត្រាជាមធ្យម ៤.០៣៥រៀលក្នុងមួយដុល្លារអាមេរិក ដោយប្រែប្រួលក្នុងកម្រិតទាបជាង ២%។ ស្ថិរភាពអត្រាប្តូរប្រាក់បានរក្សាអំណាចទិញរបស់ប្រាក់រៀល និងបានរួមចំណែកដោយផ្ទាល់ក្នុងការរក្សាស្ថិរភាពថ្លៃ។ ជាក់ស្តែង អត្រាអតិផរណាក្នុងអំឡុងពេលដូចគ្នានេះមានកម្រិតប្រមាណត្រឹមតែ ៣,២% ប៉ុណ្ណោះ។ លើសពីនេះ ស្ថិរភាពប្រាក់រៀលក៏បានរួមចំណែកពង្រឹងជំនឿទុកចិត្តរបស់សាធារណជនមកលើប្រាក់រៀល បន្ធូរបន្ថយអត្រាការប្រាក់ឥណទានជារៀល និងអភិវឌ្ឍសកម្មភាពសេដ្ឋកិច្ចនានាជាប្រាក់រៀល។ គួររំលេចថា ក្នុងរយៈពេលប៉ុន្មានឆ្នាំចុងក្រោយនេះ តួនាទីរបស់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុក្នុងទីផ្សារប្តូរប្រាក់បានកើនឡើងគួរឱ្យកត់សម្គាល់ ដោយសមាមាត្រទិញប្រាក់រៀលរបស់

គ្រឹះស្ថានទាំងនោះពីធនាគារជាតិនៃកម្ពុជាកើនឡើងពីត្រឹម ៣០% កាលពី៥ឆ្នាំមុន មកដល់ ៦០% នាពេលបច្ចុប្បន្ន។

ជារួម ប្រព័ន្ធធនាគារបានបម្រើដល់សកម្មភាពសេដ្ឋកិច្ចយ៉ាងសកម្ម និងបានលើកកម្ពស់បរិយាប័ន្នហិរញ្ញវត្ថុជាលំដាប់ ហើយបានរួមចំណែកក្នុងការគាំទ្រស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច ស្ថិរភាពហិរញ្ញវត្ថុ និងកំណើនសេដ្ឋកិច្ចប្រកបដោយចីរភាពនិងបរិយាប័ន្ន។ ការរួមចំណែករបស់វិស័យធនាគារក្នុងសកម្មភាពសេដ្ឋកិច្ចនេះ ត្រូវបានឆ្លុះបញ្ចាំងតាមរយៈកំណើននៃភាពស៊ីជម្រៅផ្នែកហិរញ្ញវត្ថុ ដែលវាស់ដោយបរិមាណផ្គត់ផ្គង់រូបិយវត្ថុធៀបនឹង ផ.ស.ស ដែលបានកើនឡើងដល់ប្រមាណ ៧៧% គឺកើនឡើងជាង៦ដង ធៀបនឹងកម្រិតកាលពីដើមទសវត្សរ៍ឆ្នាំ២០០០។ ទន្ទឹមនេះ ចំនួនប្រជាជនពេញវ័យដែលកំពុងប្រើប្រាស់សេវាហិរញ្ញវត្ថុនៅកម្ពុជាបានកើនឡើងយ៉ាងឆាប់រហ័សដល់ប្រមាណ ៥៩% នៃប្រជាជនពេញវ័យសរុប គឺកើនឡើងជាង៥ដង បើធៀបនឹង១៦ឆ្នាំមុន ដែលមានកម្រិតទាបជាង ១០% ប៉ុណ្ណោះ។

ក្នុងបរិការណ៍ដែលសេដ្ឋកិច្ចកម្ពុជាមានភាពបើកទូលាយ ធនាគារជាតិនៃកម្ពុជាបានពង្រឹងសហប្រតិបត្តិការអន្តរជាតិទាំងក្នុងក្របខ័ណ្ឌទ្វេភាគីនិងពហុភាគី ជាមួយស្ថាប័នហិរញ្ញវត្ថុអន្តរជាតិ ធនាគារកណ្តាល និងដៃគូអភិវឌ្ឍន៍នានា ទាំងក្នុងតំបន់និងពិភពលោក។ តាមរយៈការរួមចំណែកទាំងនេះ បច្ចុប្បន្ន កម្ពុជាបានក្លាយជាសមាជិកសកម្មរបស់មូលនិធិរូបិយវត្ថុអន្តរជាតិ (International Monetary Fund -IMF) ធនាគារពិភពលោក (World Bank -WB) ធនាគារអភិវឌ្ឍន៍អាស៊ី (Asian Development Bank -ADB) បន្ទាប់ពីកម្ពុជាបានបំពេញតួនាទីជាសមាជិកសារឡើងវិញ ចាប់តាំងពីដើមទសវត្សរ៍ឆ្នាំ១៩៩០មក។ ធនាគារជាតិនៃកម្ពុជាក៏

ជាសមាជិករបស់មជ្ឈមណ្ឌលស៊ាសិន (South-East Asia Training Center -SEACEN) ដែលជាមជ្ឈមណ្ឌលធ្វើការបណ្តុះបណ្តាលជំនាញសម្រាប់មន្ត្រីធនាគារកណ្តាល។ម្យ៉ាងទៀត ធនាគារជាតិនៃកម្ពុជាបានរួមចំណែកយ៉ាងសកម្ម ក្នុងការងារជំរុញសមាហរណកម្មវិស័យហិរញ្ញវត្ថុអាស៊ាន សំដៅគាំទ្រការអភិវឌ្ឍនៃសហគមន៍សេដ្ឋកិច្ចអាស៊ាន (ASEAN Economic Community -AEC) និងពង្រឹងបណ្តាញសុវត្ថិភាពហិរញ្ញវត្ថុក្នុងក្របខ័ណ្ឌអាស៊ាន+៣ ដើម្បីការពារវិបត្តិហិរញ្ញវត្ថុដែលអាចកើតឡើងជាយថាហេតុនៅក្នុងតំបន់។ ខ្ញុំសូមរំលេចផងដែរថា កន្លងមក ធនាគារជាតិនៃកម្ពុជាក៏បានដើរតួជាសហប្រធានក្នុងក្រុមការងារសមាហរណកម្មអាស៊ាន ដែលជាមោទនភាពមួយសម្រាប់មន្ត្រី-បុគ្គលិកធនាគារជាតិនៃកម្ពុជាយើង។ ធនាគារ-ជាតិនៃកម្ពុជាក៏បានក្លាយសមាជិកក្នុងស្ថាប័នអន្តរជាតិដទៃទៀតដូចជា សមាជិកសមាគមឥណទានជនបទនៃក្រុមប្រទេសអាស៊ីប៉ាស៊ីហ្វិក (Asia-Pacific Rural and Agricultural Credit Association -APRACA), ក្រុមប្រឹក្សាពិគ្រោះយោបល់ស្ថិរភាពហិរញ្ញវត្ថុប្រចាំតំបន់ (Financial Stability Board (FSB) Regional Consultative Group (RCG) for Asia), សហព័ន្ធបរិយាប័ន្នហិរញ្ញវត្ថុ (Alliance for Financial Inclusion -AFI), និងគណៈកម្មការស្ថិតិធនាគារកណ្តាលនៃធនាគារសម្រាប់ការទូទាត់អន្តរជាតិ (Bank for International Settlements -BIS) ជាដើម។

ទន្ទឹមនេះ ធនាគារជាតិនៃកម្ពុជាក៏បានបង្កើនកិច្ចសហប្រតិបត្តិការទ្វេភាគីជាមួយធនាគារកណ្តាលនិងអាជ្ញាធររូបិយវត្ថុនានា ទាំងក្នុងតំបន់និងពិភពលោកផងដែរ។ ខ្ញុំមានមោទនភាពណាស់ដែលបច្ចុប្បន្នសមត្ថភាពមន្ត្រីធនាគារជាតិនៃកម្ពុជាយើងបានកើនឡើង

ទាំងបរិមាណនិងគុណវុឌ្ឍិជាលំដាប់ ព្រមទាំងបានចែករំលែកបទពិសោធន៍ទៅឱ្យធនាគារកណ្តាលមួយចំនួនក្នុងតំបន់។

## III/- ទិសដៅនៃការអភិវឌ្ឍប្រព័ន្ធធនាគារក្នុងរយៈពេលវែង

ការទទួលបានជោគជ័យជាបន្តបន្ទាប់ក្នុងការអភិវឌ្ឍប្រព័ន្ធធនាគារនេះ គឺដោយសាររាជរដ្ឋាភិបាលបានដាក់ឱ្យអនុវត្តយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុ សម្រាប់រយៈពេលវែងប្រកបដោយជោគជ័យ ចាប់តាំងពីឆ្នាំ២០០១មក ដែលជាត្រីវិស័យច្បាស់លាស់សម្រាប់ការកំណត់និងអនុវត្តគោលនយោបាយនានា នៅក្នុងវិស័យហិរញ្ញវត្ថុ។ យុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុត្រូវបានបង្កើតឡើងក្រោមកិច្ចសហការរវាងរដ្ឋាភិបាល និងធនាគារអភិវឌ្ឍន៍អាស៊ី សម្រាប់អនុវត្តរយៈពេល ១០ឆ្នាំ។ យុទ្ធសាស្ត្រនេះមានលក្ខណៈជាផែនការរំកិល និងត្រូវបានធ្វើបច្ចុប្បន្នកម្មក្នុងរយៈពេល៥ឆ្នាំម្តង។ ការធ្វើតាមដំណាក់កាលនេះគឺដើម្បីឱ្យការអភិវឌ្ឍវិស័យធនាគារប្រព្រឹត្តទៅដោយប្រសិទ្ធភាពតាមស្ថានភាពជាក់ស្តែង ដូចអ្វីដែលអតីតប្រធានាធិបតីបារាំង លោក François Mitterand បានលើកឡើងថា ″Il faut donner du temps au temps″ មានន័យថា ការអភិវឌ្ឍមិនត្រូវឱ្យលឿនពេក ឬយឺតពេកទេ គឺឱ្យស្របនឹងស្ថានភាពនិងពេលវេលាជាក់ស្តែង។

ចាប់តាំងពីឆ្នាំ២០០១មក យុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុត្រូវបានធ្វើបច្ចុប្បន្នកម្ម ៣ដងរួចមកហើយ រួមមាន៖

- ″ចក្ខុវិស័យនិងផែនការអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុ ឆ្នាំ២០០១-២០១០″
- ″យុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុ ឆ្នាំ២០០៦-២០១៥″
- ″យុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុ ឆ្នាំ២០១១-២០២០″

- "យុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុ ឆ្នាំ២០១៦-២០២៥"។

បច្ចុប្បន្ន យុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុដែលកំពុងអនុវត្ត គ្របដណ្តប់លើឆ្នាំ ២០១៦-២០២៥។ យុទ្ធសាស្ត្រនេះមានចក្ខុវិស័យច្បាស់លាស់ដើម្បីអភិវឌ្ឍវិស័យហិរញ្ញវត្ថុមួយដែលមានលក្ខណៈប្រកួតប្រជែង សមាហរណកម្ម និងប្រសិទ្ធភាព សំដៅគាំទ្រកំណើនសេដ្ឋកិច្ចនិងកាត់បន្ថយភាពក្រីក្រ។ ក្នុងទិសដៅនេះ យុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុបានដាក់ចេញនូវផែនការសកម្មភាពចម្បងៗទៅតាមវិស័យដូចខាងក្រោម៖

i/- **ចំពោះគ្រឹះស្ថានធនាគារ៖** អាទិភាពចម្បងៗ រួមមាន៖ ការរក្សាស្ថិរភាពរូបិយវត្ថុ ស្ថិរភាពហិរញ្ញវត្ថុ ការជំរុញបរិយាប័ន្នហិរញ្ញវត្ថុ និងការលើកកម្ពស់អនុលោមភាពតាមគោលការណ៍គ្រឹះរបស់គណៈកម្មាធិការបាសែលលើការត្រួតពិនិត្យធនាគារ។

ii/- **ចំពោះគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ៖** ការងារអាទិភាព មានដូចជា៖ អនុម័តយុទ្ធសាស្ត្រស្តីពីបរិយាប័ន្នហិរញ្ញវត្ថុ បន្តយុទ្ធនាការផ្សព្វផ្សាយដល់សាធារណជន ជាពិសេសប្រជាពលរដ្ឋនៅតំបន់ជនបទ ដើម្បីជំរុញឱ្យមានការយល់ដឹងអំពីផ្នែកហិរញ្ញវត្ថុ សិក្សាស្វែងរកប្រភពទុនដែលមានតម្លៃទាប និងសិក្សាពីកត្តារួមផ្សំទាំងឡាយដែលធ្វើឱ្យថ្លៃដើមទុនខ្ពស់ និងរិះរកមធ្យោបាយដើម្បីបញ្ចុះអត្រាការប្រាក់ដោយគោរពតាមយន្តការទីផ្សារ និងបន្តពង្រឹងការអនុវត្តច្បាប់និងកិច្ចការពារអតិថិជន។

iii/- **ចំពោះប្រតិបត្តិការបង់រំលស់៖** បច្ចុប្បន្ន ប្រតិបត្តិការនេះកំពុងរីកដុះដាលគួរឱ្យកត់សម្គាល់។ ធនាគារជាតិនៃកម្ពុជាបាននិងកំពុងសហការជាមួយនឹងស្ថាប័នពាក់ព័ន្ធ ដើម្បីរៀបចំយន្តការនិងបទប្បញ្ញត្តិសម្រាប់គ្រប់គ្រងឱ្យកាន់តែមានប្រសិទ្ធភាព។

iv/- **ចំពោះភតិសន្យាហិរញ្ញវត្ថុ៖** ចាប់តាំងពីក្របខ័ណ្ឌបទប្បញ្ញត្តិបានពង្រឹងចាប់ពីឆ្នាំ ២០០៩មក ប្រតិបត្តិការភតិសន្យាហិរញ្ញវត្ថុ មានការរីកចម្រើនជាលំដាប់។ ធនាគារជាតិនៃកម្ពុជានឹងបន្តពង្រឹងបទប្បញ្ញត្តិប្រុងប្រយ័ត្ននានា ដើម្បីកាត់បន្ថយហានិភ័យក្នុងអាជីវកម្មនេះ និងកែលម្អទម្រង់របាយការណ៍ ដើម្បីទទួលបានព័ត៌មានគ្រប់គ្រាន់ក្នុងការវិភាគ និងតាមដានការវិវត្តនៃប្រតិបត្តិការនេះ ដើម្បីធ្វើឱ្យវិស័យនេះ កាន់តែចូលរួមក្នុងការអភិវឌ្ឍសហគ្រាសធុនតូចនិងមធ្យម ជាពិសេសក្នុងវិស័យកសិកម្មនិងសិប្បកម្ម។

v/- **ចំពោះការអភិវឌ្ឍទីផ្សារអន្តរធនាគារនិងទីផ្សាររូបិយវត្ថុ៖** ឧបករណ៍គោលនយោបាយរូបិយវត្ថុនានានឹងត្រូវបន្តអភិវឌ្ឍនិងបង្កើតថ្មី ដើម្បីជំរុញការអភិវឌ្ឍទីផ្សារនេះឱ្យដំណើរការល្អ ស្របតាមយន្តការទីផ្សារ។

vi/- **ចំពោះការគ្រប់គ្រងការចែករំលែកព័ត៌មានឥណទាន៖** បន្តពង្រឹងការត្រួតពិនិត្យការិយាល័យឥណទានកម្ពុជា ដោយផ្តោតការយកចិត្តទុកដាក់លើបច្ចេកវិទ្យា សមត្ថភាព សុវត្ថិភាព និងកិច្ចការពារអ្នកប្រើប្រាស់ និងរៀបចំរបាយការណ៍ព័ត៌មានឥណទានពាណិជ្ជកម្មដែលគ្របដណ្តប់លើការផ្តល់កម្ចីទាំងអស់ទៅឱ្យក្រុមហ៊ុន និងបុគ្គលក្នុងនាមជាក្រុមហ៊ុនឬសាជីវកម្ម។

vii/- **ចំពោះប្រព័ន្ធទូទាត់សងប្រាក់៖** បន្តពង្រឹងក្របខ័ណ្ឌបទប្បញ្ញត្តិ វិធានការ និងនីតិវិធី ដើម្បីសម្រេចឱ្យបានការដាក់ឱ្យប្រើប្រាស់បច្ចេកវិទ្យាថ្មីៗ ព្រមទាំងតភ្ជាប់ប្រព័ន្ធទូទាត់សងប្រាក់របស់កម្ពុជា ជាមួយនឹងប្រព័ន្ធទូទាត់សងប្រាក់របស់ប្រទេសដទៃនៅក្នុងតំបន់និងទូទាំងសកលលោក។

ដើម្បីដើរឱ្យទាន់ការរីកចម្រើនដ៏ឆាប់រហ័សនៃវិស័យធនាគារ ការកើនឡើងនៃចំនួនមន្ត្រី-បុគ្គលិក និងលើកកម្ពស់ប្រសិទ្ធភាពការងារ ធនាគារជាតិនៃកម្ពុជានឹងសង់អគារថ្មីនៅទីតាំងចាស់នៅឆ្នាំក្រោយនេះ។ យើងសង្ឃឹមថា អគារថ្មីធនាគារជាតិនៃកម្ពុជានេះនឹងរួមចំណែកផងដែរក្នុងការលើកសោភ័ណ្ឌភាពរាជធានីភ្នំពេញ និងបង្ហាញពីភាពរឹងមាំនៃប្រព័ន្ធធនាគារកម្ពុជា។ ឆ្លៀតក្នុងឱកាសនេះ ខ្ញុំក៏សូមជូនដំណឹងដល់ឯកឧត្តម លោកជំទាវ លោក លោកស្រី នាងកញ្ញាទាំងអស់ថា សារមន្ទីរសេដ្ឋកិច្ចនិងរូបិយវត្ថុ **"ព្រះស្រីល្បសានវរ្ម័ន"** គ្រោងនឹងបើកទ្វារនៅដើមឆ្នាំ២០១៨ នេះ។ សារមន្ទីរសេដ្ឋកិច្ចនិងរូបិយវត្ថុ **"ព្រះស្រីល្បសានវរ្ម័ន"** នឹងដាក់បង្ហាញពីប្រវត្តិរីកចម្រើននៃប្រព័ន្ធរូបិយវត្ថុកម្ពុជា តាំងពីសម័យហ្វូណន រហូតមកដល់បច្ចុប្បន្ន។ សារមន្ទីរនេះ ក៏មានគោលបំណងផ្តល់ជូនយុវជននូវចំណេះដឹងពីដំណើរ និងការអភិវឌ្ឍសេដ្ឋកិច្ច ធនាគារ និងរូបិយវត្ថុផងដែរ។

**ឯកឧត្តម លោកជំទាវ លោក លោកស្រី នាងកញ្ញា ជាទីមេត្រី !**

សរុបមក សមិទ្ធផលសេដ្ឋកិច្ចនិងសង្គមក្នុងរយៈពេល ៣៨ឆ្នាំកន្លងមកនេះ កើតឡើងដោយសារកិច្ចខិតខំប្រឹងប្រែងរបស់រាជរដ្ឋាភិបាលក្នុងការរក្សាសន្តិភាព ស្ថិរភាពនយោបាយ និងសណ្តាប់ធ្នាប់សង្គម និងជោគជ័យក្នុងការអនុវត្តគោលនយោបាយចតុកោណ និងយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុរបស់រាជរដ្ឋាភិបាល ដែលមានសម្តេចតេជោ ហ៊ុន សែន ជាអគ្គមគ្គុទេសក៍។ ទន្ទឹមនេះ ការអភិវឌ្ឍវិស័យធនាគារក៏ទទួលបានការរួមចំណែកមិនអាចខ្វះបានរបស់មន្ត្រី-បុគ្គលិកគ្រប់លំដាប់ថ្នាក់របស់ធនាគារជាតិនៃកម្ពុជា ដែលបានបំពេញការងារប្រកបដោយស្មារតីទទួលខុសត្រូវខ្ពស់ ព្រមទាំងមានការចូលរួមសហការល្អពីក្រសួង-ស្ថាប័ន និងដៃគូអភិវឌ្ឍន៍នានាផងដែរ។

ដើម្បីឱ្យអង្គពិធីនាថ្ងៃនេះប្រព្រឹត្តទៅដោយសកម្មនិងមានការចូលរួមរបស់យុវជនយើង យើងក៏បានរៀបចំកិច្ចពិភាក្សាចំនួនពីរ ៖ ទី១/- លើប្រធានបទ ″ប្រាក់រៀលនិងការអភិវឌ្ឍសេដ្ឋកិច្ចជាតិ″ និងទី២/- លើប្រធានបទ ″តម្លៃសន្តិភាពក្នុងការអភិវឌ្ឍសេដ្ឋកិច្ចជាតិជាពិសេសវិស័យធនាគារនិងហិរញ្ញវត្ថុ″។

ជាទីបញ្ចប់ ខ្ញុំសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះ ឯកឧត្តម លោកជំទាវ លោក លោកស្រី នាងកញ្ញា ទាំងអស់ដែលមានវត្តមានក្នុងអង្គពិធីនេះ។ ខ្ញុំសូមអបអរសាទរខួបអនុស្សាវរីយ៍លើកទី៣៨នៃការបង្កើតធនាគារជាតិនៃកម្ពុជាឡើងវិញ និងជូនពរឱ្យពិធីយើងប្រព្រឹត្តទៅដោយជោគជ័យ។

**សូមអរគុណ**!